# ប្រភេទ ទី១ : ភ្លើងសញ្ញាចរាចរ បីពណ៌ ( Three Colored Traffic Lights )


01a.


01b.


01c.

## ភ្លើងសញ្ញាចរាចរបីពណ៌ ជារង្វង់

THREE COLORED CIRCULAR LIGHTS

**លេខកូដ :PW03-L1-01**

**ខ្លឹមសារ :** ភ្លើងសញ្ញានេះ ប្រើសំរាប់បញ្ជានិងសំរួលចរាចរ មួយ ឬ ច្រើនគន្លង រួមគ្នា នៅត្រង់ផ្លូវប្រសព្វ ឬ ត្រង់ផ្លូវមាន គំនូសសញ្ញាសំរាប់ថ្មើរជើងឆ្លងកាត់ ។

ពណ៌និមួយៗនៃភ្លើងសញ្ញា មានអត្ថន័យដូចខាងក្រោម:

-ពណ៌ក្រហម ( រូប **01a.** ):

ត្រូវឈប់នៅមុខ គំនូសសញ្ញាឈប់ ។

-ពណ៌លឿង ( រូប **01b.** ):

ត្រូវប្រុងប្រយត្ន័ ត្រៀមឈប់ ប៉ុន្តែបើអ្នកបើកបរ ចូលកៀកផ្លូវប្រសព្វ ឬគំនូសសញ្ញាថ្មើរជើងឆ្លងកាត់ ដែលពុំអាចបញ្ឈប់យានរបស់ខ្លួនបាន ដោយសុវត្ថិភាព គេអាចបន្តដំណើរបាន ដោយប្រុងប្រយត្ន័ ។

-ពណ៌បៃតង ( រូប **01c.** ):

អនុញ្ញាតបន្តដំណើរបាន បើផ្លូវទំនេរ និង ជឿជាក់ថាអាច ឆ្លងផុតផ្លូវប្រសព្វ ដោយមិនបង្កភាពកកស្ទះ ។

ក្នុងករណី មានភ្ជាប់បន្ថែម សញ្ញាព្រួញ ពណ៌បៃតងចង្អុលទៅខាងស្តាំ ដូចក្នុង រូប **01d.** ( អាចជាភ្លើងអគ្គីសនី ឬ ជាផ្ទាកគំនូរ ) នៅពេលមានភ្លើងក្រហម អាចអនុញ្ញាតបត់ស្តាំបានដោយប្រុងប្រយត្ន័ ប្រសិនបើផ្លូវទំនេរ ។


01d.

---

## ភ្លើងសញ្ញាចរាចរ សំរាប់ថ្មើរជើងឆ្លងកាត់
## (ប្រើជាមួយ ភ្លើងសញ្ញាចរាចរបីពណ៌ ជារង្វង់ )

PEDESTRIAN CROSSING LIGHTS
( USED WITH THREE COLORED CIRCULAR LIGHTS )

**លេខកូដ :PW03-L1-02**

**ខ្លឹមសារ :** ភ្លើងសញ្ញាប្រភេទនេះ ប្រើជាមួយ ភ្លើងសញ្ញាចរាចរបីពណ៌ជារង្វង់ សំរាប់បញ្ជា និង សំរួល ចរាចរដល់ថ្មើរជើង ក្នុងការដើរឆ្លងកាត់ផ្លូវ ។


02a.


02b.

ពណ៌និមួយៗនៃភ្លើងសញ្ញា មានអត្ថន័យដូចខាងក្រោម:

-ពណ៌ក្រហម ដែលមានរូបមនុស្សពណ៌ស ឈរខាងក្នុង (រូប **02a.**):

ត្រូវឈប់, ហាមឆ្លងកាត់ ។

-ពណ៌បៃតង ដែលមានរូបមនុស្សពណ៌ស ដើរខាងក្នុង (រូប **02b.**):

អនុញ្ញាតអោយដើរឆ្លងកាត់បាន ។



03a. 03b. 03c.

## ភ្លើងសញ្ញាចរាចរបីពណ៌ ជាព្រួញ (ទៅមុខត្រង់)

THREE COLORED ARROW LIGHTS (STRAIGHT THROUGHT)

**លេខកូដ :PW03-L1-03**

**ខ្លឹមសារ :** ភ្លើងសញ្ញានេះ ប្រើនៅត្រង់ផ្លូវប្រសព្វ សំរាប់បញ្ជា និងសំរួលចរាចរ ដល់គន្លងផ្លូវនិមួយៗ ដែលអនុញ្ញាតអោយធ្វើចរាចរ តែទៅមុខត្រង់ ។

ពណ៌និមួយៗនៃភ្លើងសញ្ញាចរាចរនេះ ( រូប 03a. 03b. 03c.) មានអត្ថន័យដូចភ្លើងសញ្ញា បីពណ៌ជារង្វង់ដែរ ។

---



04a. 04b. 04c.

## ភ្លើងសញ្ញាចរាចរបីពណ៌ ជាព្រួញ (បត់ស្តាំ)

THREE COLORED ARROW LIGHTS (RIGHT TURN )

**លេខកូដ :PW03-L1-04**

**ខ្លឹមសារ :** ភ្លើងសញ្ញានេះ ប្រើនៅត្រង់ផ្លូវប្រសព្វ សំរាប់បញ្ជា និងសំរួលចរាចរ ដល់គន្លងផ្លូវនៅខាងស្តាំ ដែលអនុញ្ញាតអោយធ្វើចរាចរ បានតែបត់ស្តាំ ។

ពណ៌និមួយៗនៃភ្លើងសញ្ញាចរាចរនេះ ( រូប 04a. 04b. 04c.) មានអត្ថន័យដូចភ្លើងសញ្ញា បីពណ៌ជារង្វង់ដែរ ។

---



05a. 05b. 05c.

## ភ្លើងសញ្ញាចរាចរបីពណ៌ ជាព្រួញ (បត់ឆ្វេង)

THREE COLORED ARROW LIGHTS (LEFT TURN )

**លេខកូដ :PW03-L1-05**

**ខ្លឹមសារ :** ភ្លើងសញ្ញានេះ ប្រើនៅត្រង់ផ្លូវប្រសព្វ សំរាប់បញ្ជា និងសំរួលចរាចរ ដល់គន្លងផ្លូវនៅខាងឆ្វេង ដែលអនុញ្ញាតអោយធ្វើចរាចរ បានតែបត់ឆ្វេង ។

ពណ៌និមួយៗនៃភ្លើងសញ្ញាចរាចរនេះ ( រូប 05a. 05b. 05c.) មានអត្ថន័យដូចភ្លើងសញ្ញា បីពណ៌ជារង្វង់ដែរ ។


06a.


06b.


06c.

## ភ្លើងសញ្ញាចរាចរបីពណ៌ ជាព្រួញ (ទៅមុខត្រង់ និង បត់ស្តាំ)

THREE COLORED ARROW LIGHTS
(STRAIGHT THROUGHT AND RIGHT TURN )

**លេខកូដ :PW03-L1-06**

**ខ្លឹមសារ** : ភ្លើងសញ្ញានេះ ប្រើនៅត្រង់ផ្លូវប្រសព្វ សំរាប់បញ្ជា និង សំរួលចរាចរ ដល់គន្លងផ្លូវនិមួយៗ ដែលអនុញ្ញាត អោយធ្វើចរាចរ តែទៅមុខត្រង់ ឬ បត់ស្តាំ ។

ពណ៌និមួយៗនៃភ្លើងសញ្ញាចរាចរនេះ ( រូប 06a. 06b. 06c.) មានអត្ថន័យដូចភ្លើងសញ្ញា បីពណ៌ជារង្វង់ដែរ ។

---


07a.


07b.


07c.

## ភ្លើងសញ្ញាចរាចរបីពណ៌ ជាព្រួញ (ទៅមុខត្រង់ និង បត់ឆ្វេង)

THREE COLORED ARROW LIGHTS
(STRAIGHT THROUGHT AND LEFT TURN )

**លេខកូដ :PW03-L1-07**

**ខ្លឹមសារ** : ភ្លើងសញ្ញានេះ ប្រើនៅត្រង់ផ្លូវប្រសព្វ សំរាប់បញ្ជា និង សំរួលចរាចរ ដល់គន្លងផ្លូវនិមួយៗ ដែលអនុញ្ញាត អោយធ្វើចរាចរ តែទៅមុខត្រង់ ឬ បត់ឆ្វេង ។

ពណ៌និមួយៗនៃភ្លើងសញ្ញាចរាចរនេះ ( រូប 07a. 07b. 07c.) មានអត្ថន័យដូចភ្លើងសញ្ញា បីពណ៌ជារង្វង់ដែរ ។

---



08a.



08b.

## ភ្លើងសញ្ញាចរាចរ សំរាប់ថ្មើរជើងឆ្លងកាត់ (ប្រើជាមួយ ភ្លើងសញ្ញាចរាចរបីពណ៌ ជាព្រួញ )

PEDESTRIAN CROSSING LIGHTS
( USED WITH THREE COLORED ARROW LIGHTS )

**លេខកូដ :PW03-L1-08**

**ខ្លឹមសារ** : ភ្លើងសញ្ញាប្រភេទនេះ ប្រើជាមួយ ភ្លើងសញ្ញាចរាចរ បីពណ៌ជាព្រួញ សំរាប់បញ្ជា និង សំរួលចរាចរដល់ ថ្មើរជើង ក្នុងការដើរឆ្លងកាត់ផ្លូវ ។

ពណ៌និមួយៗនៃភ្លើងសញ្ញា មានអត្ថន័យដូចខាងក្រោម:

- លេខ និង រូបមនុស្សឈរ ពណ៌ក្រហម លើផ្ទៃពណ៌ខ្មៅ (រូប **08a.**): **ត្រូវឈប់ ឬ ហាមឆ្លងកាត់** ។ លេខពណ៌ក្រហម ប្រាប់រយៈពេលគិតជាវិនាទី ដែលនឹងប្តូរមក ជាពណ៌បៃតងវិញ ។
- លេខ និង រូបមនុស្សធ្វើចលនាដើរ ពណ៌ខៀវ លើផ្ទៃពណ៌ខ្មៅ (រូប **08b.**): **អនុញ្ញាតអោយដើរឆ្លងកាត់បាន** ។ លេខពណ៌បៃតង ប្រាប់រយៈពេលគិតជាវិនាទី ដែលនឹងប្តូរមកជាពណ៌ក្រហមវិញ ។